**មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

**កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៊ែម តំបន់ទី ១**

**យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២**

**ថ្ងៃ អង្គារ ទី២២ ខែវិច្ឆិកា ឆ្នាំ២០០៥**

**ខេត្ត តាកែវ**

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈនៃកិច្ចប្រជុំ**

១. សុន្ទរកថាបើកជាផ្លូវការនៃយន្តការខប់សែលប្រ៊មទូទាំងព្រះរាជាណាចក្រកម្ពុជា ថ្លែងដោយឯកឧត្តម **កង សំអឿន** អភិបាលរងខេត្តតាកែវ និងជាតំណាងឯកឧត្តម **ស៊ូ ភិរិន្ទ** អភិបាលខេត្តតាកែវ

២. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក **ប៉ែន ឡុង** ប្រធានលេខាធិការដ្ឋាន រៀបចំការបោះឆ្នោតខេត្តតាកែវ

៣. មតិរបស់អ្នកចូលរួមបង្ហាញពីការខិតខំទាំងឡាយនៅក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តតាកែវ

៤. សេចក្តីផ្សេងៗ

លោក **ឱក សេរី សោភ័ក្តិ៍** ទីប្រឹក្សានៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(វបសអ) និងជាអ្នកសម្របសម្រួលកិច្ចប្រជុំខប់សែល បានស្វាគមន៍ឯកឧត្តម និង សមាជិកអង្គប្រជុំដែលបានចំណាយពេលដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខប់សែលប្រ៊ម នៅតំបន់ទី១ នៃយន្តការខប់សែលដំណាក់កាលទី ២ នេះ និងបានជំរាបជូនអង្គប្រជុំពីរបៀបវារៈប្រជុំសំរាប់ថ្ងៃនេះ ។

## ១. សុន្ទរកថាបើកជាផ្លូវការនៃយន្តការខប់សែលប្រ៊ម ទូទាំងព្រះរាជាណាចក្រកម្ពុជា ថ្លែងដោយឯកឧត្តម កង សំអឿន អភិបាលរងខេត្តតាកែវ និងជាតំណាងឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តតាកែវ

ក្នុងនាមឯកឧត្តម **ស៊ូ ភិរិន្ទ** អភិបាលខេត្តតាកែវ និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តមបានសំដែងការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និង ការគាំទ្រយ៉ាងពេញទំហឹងចំពោះវិទ្យាស្ថាន **CDRI** ដែលបានបង្កើតយន្តការខប់សែលនេះឡើង ដើម្បីសិក្សាស្រាវជ្រាវឫសគល់ទំនាស់ ក្នុងការបោះឆ្នោតនៅកម្ពុជា ។ ឯកឧត្តមបានរំលឹកឡើងថា ខប់សែលតំណាក់កាលទី១ ចាប់ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជួយជំរុញឱ្យដំណើរការនៃការបោះឆ្នោតកន្លងមកប្រព្រឹត្តទៅកាន់តែប្រសើរទៅជា បណ្តើរៗ និង ឈានទៅការកសាងវប្បធម៌មួយនៃការពិភាក្សាគ្នាដើម្បីស្វែងយល់ ជឿជាក់គ្នា និង រកដំណោះស្រាយរួមប្រកបដោយន័យស្ថាបនា ។ ខប់សែល បានឈានជាបណ្តើរៗរហូតមកដល់សព្វថ្ងៃនេះដោយបើកទស្សនៈកាន់តែទូលំទូលាយដោយបំបែកខប់សែលក្នុងតំណាក់កាល ទី២នេះពីឆ្នាំ២០០៦ ដល់ឆ្នាំ ២០០៨ ជាច្រើនរចនាសម្ព័ន្ធទៀត ដើម្បីធ្វើឱ្យវប្បធម៌នៃ ការពិភាក្សាគ្នាចូលជ្រៅទៅដល់ប្រជាពលរដ្ឋមូលដ្ឋាន ។ ដូច្នេះ នេះជាឱកាសដ៏ថ្លៃថ្លាបំផុតដែលខេត្តតាកែវបានទទួលវប្បធម៌ថ្មីមួយទៀតដែលយើងទាំងអស់គ្នាអង្គុយនៅទីនេះកំពុងតែគិតថាត្រូវធ្វើយ៉ាងដូចម្តេច ចំពោះការបោះឆ្នោតពាលើកនាពេលខាងមុខ ។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមបានលើកយកករណីមកបញ្ជាក់ជូនអង្គប្រជុំទាំងមូលដើម្បីជាមូលដ្ឋានសំរាប់ពិចារណា និងស្វែងយល់ទាក់ទងនឹងការបោះឆ្នោតកន្លងមក ដែលជាធម្មតារាល់ការបោះឆ្នោតតែងតែមានទំនាស់ជាដរាប ហើយមិនដែលប្រទេសណាមួយ ជៀសផុតនោះទេ សូម្បីប្រទេសធំៗដែលមានលិទ្ធិប្រជាធិបតេយ្យចាក់គ្រឹះយ៉ាងមាំក៏ដោយ ។ បើប្រៀបធៀបទៅនឹងប្រទេសកម្ពុជាយើង ការចូលរួមបោះឆ្នោត របស់ប្រជាពលរដ្ឋយើងមានចំនួនរហូតដល់ ៩០ ភាគរយច្រើនជាងបណ្តាប្រទេសទាំងនោះដែលមានអ្នកចូលរួមបោះឆ្នោតតែប្រមាណ ៤០ ទៅ ៦០ ភាគរយប៉ុណ្ណោះ។ ដូច្នេះយើងទាំងអស់គ្នាគួរតែមានមោទនភាពចូលរួមកាត់បន្ថយទំនាស់ និងកសាងទំនុកទុកចិត្តគ្នាទៅវិញទៅមកដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យឱ្យកាន់តែរឹងមាំឈានទៅការគោរពសិទ្ធិមនុស្សឱ្យបានល្អប្រសើរនៅកម្ពុជា។

ឯកឧត្តមមានជំនឿយ៉ាងមុតមាំថា ខប់សែលថ្នាក់ខេត្តលើកទី១ នឹងបំពេញតួនាទីជាអាជ្ញាកណ្តាលដ៏សំខាន់មានអព្យាក្រឹតភាពក្នុងការស្វែងរកបញ្ហាជាគន្លឹះធំៗដើម្បីសម្របសម្រួលឱ្យដំណើរការបោះឆ្នោតបីលើកខាងមុខប្រព្រឹត្តទៅដោយរលូនគ្មានទំនាស់ គ្មានអំពើហិង្សា ដែលប្រជាជនកម្ពុជាយើងចង់បាន ។

## ២. សភាពការណ៍ទូទៅនៃការរៀបចំការបោះឆ្នោត

លោក **ឱក សេរី សោភក្តិ** បានជំរាបអង្គប្រជុំអំពីខប់សែល តំណាក់កាលទី ២ ទទួលបានការគាំទ្រ ទាំងស្រុងពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ សំរាប់ដំណើរការបីឆ្នាំខាងមុខនេះ និងមានរចនាសម្ព័ន្ធខុសប្លែកពីខប់សែលតំណាក់កាលទី ១ ដោយពេលនេះខប់សែល មានបើកទូលាយសំរាប់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងនៅភ្នំពេញ និង តាមបណ្តាខេត្ត និង សារព័ត៌មានពិសេសនៅតាមមូលដ្ឋាន ដើម្បីយល់ឱ្យបានជ្រួតជ្រាប និង ចូលរួមឱ្យបានសកម្មក្នុងដំណើរការបោះឆ្នោតនៅកម្ពុជា ។ លោកក៏បានបញ្ជាក់បន្ថែមថា ខប់សែលតំណាក់កាលទី ២ ដែលរូបលោកបានខិតខំបង្កើតដោយផ្ទាល់នេះ គឺដើម្បីចូលរួមចំណែកជាមួយ គជប និងជាមួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តគោលនយោបាយកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ និងដើម្បីជួយកសាង និងពង្រឹងវប្បធម៌នៃការពិភាក្សាគ្នានេះឱ្យកើតមានរហូតដល់ថ្នាក់មូលដ្ឋាន ។ លោកក៏បានជំរាបផងដែរអំពីនីតិវិធីរដ្ឋបាលរបស់ខប់សែល ដែលរាល់កិច្ចប្រជុំទាំងអស់សុទ្ធតែមានថតសំលេងទុកជាឯកសារដើម្បីធ្វើកំណត់ហេតុ ហើយកំណត់ហេតុទាំងអស់នឹងផ្ញើរថ្វាយព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ និងជូនសមាជិកសភា ព្រឹទ្ធសភា ប្រមុខរាជរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ សមាជិកគជប ក្រុមប្រឹក្សាធម្មនុញ្ញ ស្ថានទូតបរទេសប្រចាំនៅកម្ពុជា អង្គការជាតិ អន្តរជាតិ លោកអភិបាលខេត្ត អភិបាលរងខេត្ត និង លោកអភិបាលស្រុក និង មេឃុំជាដើម ដើម្បីជ្រាបជាព័ត៌មាន អំពីលទ្ធផលកិច្ចពិភាក្សាទាំងនេះ ។

លោក **ប៉ែន ឡុង** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តតាកែវ បានជំរាបជូនអង្គប្រជុំអំពីសភាពការណ៍ទូទៅនៃការបោះឆ្នោតតាំងពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ២០០៣ កន្លងមកនេះ ។ ទាក់ទងនឹងច្បាប់ក្នុងកិច្ចប្រតិបត្តិការនៃការរៀបចំការបោះឆ្នោតនីមួយៗ យើងបានកំណត់យកច្បាប់បោះឆ្នោតធ្វើជាច្បាប់គោល និងអនុវត្តន៍តាមបទបញ្ជា និងនីតិវិធី សំរាប់ការបោះឆ្នោតរបស់ គជប ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀតដែលមានជាធរមាន ។ ទោះបីជាបទបញ្ជា និង នីតិវិធីសំរាប់ការបោះឆ្នោត បានចែងយ៉ាងលំអិតក៏ដោយ ក៏នៅមានវិសោធនកម្មទៅលើប្រការមួយចំនួនជាបន្តបន្ទាប់ ដើម្បីសម្រួលឱ្យការអនុវត្តមានប្រសិទ្ធភាពជាងមុន ហើយឆ្លើយតបបានទាន់ពេលវេលាទៅនឹងតំរូវការជាក់ស្តែងនៅមូលដ្ឋាន ។ ទាក់ទងនឹងការងារឃោសនាអប់រំផ្សព្វផ្សាយជូនសាធារណៈជនក្នុងគោលបំណងឱ្យប្រជាពលរដ្ឋគ្រប់ៗរូបមានសិទ្ធិយល់ដឹងអំពីបែបបទ នៃការបោះឆ្នោតសំងាត់ និងសេរីភាពពេញលេញជូនគណបក្សនយោបាយ លើបេក្ខជនណាដែលខ្លួនពេញចិត្ត ជាពិសេសអប់រំអ្នកបោះឆ្នោតឱ្យដឹងច្បាស់ពីពេលវេលា ទីកន្លែងត្រូវទៅចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត និង សារៈប្រយោជន៍ផ្សេងៗទៀត ។ មុននិងចាប់ផ្តើមការឃោសនាការបោះឆ្នោតតំណាងគណបក្សនយោបាយបានចុះហត្ថលេខាលើគោលការណ៍ក្រមសីលធម៌សំរាប់ការឃោសនា ដោយអាជ្ញាធររៀបចំការបោះឆ្នោតជាអ្នកសំរបសំរួល និងរៀបចំប្រតិទិនដើម្បីបញ្ចៀសនូវការប៉ះទង្គិចគ្នាក្នុងពេលឃោសនា និងបានរៀបចំកិច្ចប្រជុំមួយសប្តាហ៍ម្តងជាមួយគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អាជ្ញាធរខេត្ត សមត្ថកិច្ចនគរបាល និងកងរាជអាវុធហត្ថ ដើម្បីសម្របសម្រួលរាល់បញ្ហាដែលកើតមានឡើង និងបង្ការទំនាស់ អំពើហិង្សានានា ដែលនាំឱ្យជះឥទ្ធិពលមិនល្អដល់ការបោះឆ្នោត ។

ទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ឆ្នាំ២០០២ PEC ខេត្តតាកែវ មានមន្ត្រីចុះឈ្មោះចំនួន ១៤០ក្រុម ស្មើនឹង៨៤០នាក់សំរាប់ប្រតិបត្តិការចុះឈ្មោះបោះឆ្នោត រយៈពេលពី១៥ថ្ងៃរហូតដល់២៧ថ្ងៃ និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតគឺផ្អែកទៅលើបញ្ជីបោះឆ្នោតចុងក្រោយ ជ្រើសតាំងតំណាងរាស្ត្រអណត្តិទី២ ឆ្នាំ ១៩៩៨ ។ ដោយឡែកសំរាប់ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣ PEC ខេត្តតាកែវពុំមានមន្ត្រីចុះឈ្មោះបោះឆ្នោតទៀតទេ ព្រោះ គជប បានធ្វើប្រតិភូកម្មអំណាចជូនក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ហើយនៅពេលនោះលេខាធិការដ្ឋានខេត្តរៀបចំការបោះឆ្នោតដើរតួជាអ្នកគ្រប់គ្រងឯកសារ និងសម្របសម្រួលបច្ចេកទេស និងនីតិវិធីតែប៉ុណ្ណោះ ។ លោកក៏បានលើកឡើងផងដែរអំពីការធ្វើបច្ចុប្បន្នភាព បញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៥ នេះ ដោយទទួលបានលទ្ធផលសរុបមានចំនួនប្រជាពលរដ្ឋដែលមានអាយុ ១៨ ឆ្នាំឡើងមាន ៤៩២.២២៦ នាក់ ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីចុងឆ្នាំ២០០៤ មាន ៤៧១.៥២៤នាក់ ចំនួនអ្នកដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ ២០០៤ មានចំនួន ៤.៥៤៧ នាក់ចំនួនអ្នកចុះឈ្មោះបោះឆ្នោតថ្មីគឺចុះឈ្មោះក្នុងឆ្នាំ ២០០៥ នេះបាន ១៩.៧៦០ នាក់ ។ សរុប អ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០០៥ មានចំនួន ៤៨៦.៧៣៧ នាក់ (៩៨.៨៨%) ។ លោកបានវាយតំលៃថា ការបោះឆ្នោតកន្លងមកបានប្រព្រឹត្តទៅក្នុងបរិយាកាសសេរីត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព អាចទទួលយកបានពីភាគីប្រកួតប្រជែង និងដោយ មានការទទួលស្គាល់ពីអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិថា មិនមានអំពើហិង្សាដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការបោះឆ្នោតឡើយ ។ បណ្ដឹងទាំងឡាយដែលទទួលបានត្រូវដោះស្រាយតាមបែបបទនីតិវិធីរួចរាល់ តែមានបណ្ដឹងចំនួន ២ ប៉ុណ្ណោះ ដែលដើមបណ្ដឹងបន្តប្ដឹង ទៅ គជប ។ តាមការកត់សំគាល់របស់លោកឃើញថាមានការរំលោភបំពានខ្លះៗ លើនីតិវិធីនៃការបោះឆ្នោតដោយគណបក្សនយោបាយខ្លះ បានប្រើពាក្យសំដីវាយប្រហារធ្ងន់ៗ ទៅលើគណបក្សដ៏ទៃទៀត និងទៅលើបុគ្គលដោយប្រើពាក្យមិនសមរម្យ អសីលធម៌ ប្រមាថមើលងាយ ។ល។ ភ្នាក់ងារគណបក្សនយោបាយខ្លះ មិនបានប្រកាន់តាមក្រមសីលធម៌ឡើយ ។ ភ្នាក់ងារគណបក្សនយោបាយមួយចំនួនមិនព្រមចុះហត្ថលេខាលើកំណត់ហេតុបោះឆ្នោតរាប់សន្លឹកឆ្នោតខណៈពេលដែលខ្លួនរកមិនឃើញភាពមិនប្រក្រតីណាមួយសោះ ។ អ្នកសង្កេតការណ៍អង្គការសង្គមស៊ីវិលខ្លះបានបង្គាប់បញ្ជាមន្ត្រីបោះឆ្នោត ។

លោកក៏បានផ្ដល់ជាអនុសាសន៍មួយចំនួនសំរាប់អនុវត្តនៅពេលខាងមុខដូចខាងក្រោម:

១- បន្តផ្សព្វផ្សាយឱ្យបានទូលាយជូនប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតអំពីសិទ្ធិ និងករណីកិច្ចក្នុងការចូលរួមបោះឆ្នោត ។

២- ពង្រឹងសកម្មភាពរបស់គណបក្សនយោបាយឱ្យបានត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធី របស់ គជប ព្រមទាំងក្រមសីលធម៌របស់គណបក្សនយោបាយ ទប់ស្កាត់ និងផាកពិន័យយ៉ាងម៉ឺងម៉ាត់ចំពោះសកម្មជនរបស់គណបក្សនយោបាយ ដែលរំលោភបំពានទៅលើគោលការណ៍ច្បាប់ បទបញ្ជា និងនីតិវិធីសំរាប់ការបោះឆ្នោត ។

៣- លើកកំពស់ការចូលរួមសកម្មភាពរបស់អង្គការសង្គមស៊ីវិលក្នុងការអប់រំបណ្ដុះបណ្ដាលភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីដំណើរការបោះឆ្នោត ។

៤- ពង្រឹងយន្តការដោះស្រាយទំនាស់នៅក្នុងគ្រប់ជំហានការងារនៃដំណើរការរៀបចំការបោះឆ្នោត ជាពិសេសយន្តការរបស់អាជ្ញាធរថ្នាក់មូលដ្ឋាន ។

៥- គ្រប់គណបក្សនយោបាយគប្បីគោរពសំលេងឆ្នោតរបស់ប្រជាពលរដ្ឋ ដោយព្រមចុះហត្ថលេខាទទួលយកលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ដើម្បីបំពេញតួនាទីរបស់ខ្លួនយ៉ាងថ្លៃថ្នូរតាមច្បាប់ ។

៦- គ.ជ.ប គប្បីសម្រួលពេលវេលាពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំដល់ឃុំ ដែលស្ថិតនៅតំបន់លិចទឹក ។ លោកសង្ឃឹមថាគ្រប់គណបក្សនយោបាយ អង្គការសង្គមស៊ីវិលនានា ស្ថាប័នសាធារណៈ និង ប្រជាពលរដ្ឋគ្រប់រូប រួមគ្នាប្រកបដោយស្មារតីស្នេហាជាតិក្នុងការពង្រឹងការអនុវត្តន៍គោលការណ៍ប្រជាធិបតេយ្យ និង ច្បាប់រដ្ឋដើម្បីឱ្យប្រទេសកម្ពុជាក្លាយជានីតិរដ្ឋពិតប្រាកដក្នុងអនាគតដ៏ខ្លី ។

លោក **ឱក សេរី សោភក្តិ៍** បានជំរាបជូនអង្គប្រជុំអំពីគោលបំណងចំបង ៣ របស់យន្តការខប់សែលប្រ៉ម គោលដៅធំទី១ ធ្វើយ៉ាងណា យុទ្ធនាការជាមួយរដ្ឋាភិបាលជាពិសេសក្រសួងមហាផ្ទៃ និងឯកឧត្តមអភិបាលខេត្តទាំងអស់ធ្វើឱ្យបញ្ហាអត្តសញ្ញាណប័ណ្ណនេះ ឈប់ជាបញ្ហាទៀតឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ ទទួលបានអត្តសញ្ញាណប័ណ្ណគ្រប់គ្នាតែម្តង ។ មានដំណឹងមកថា **UNDP** មានគំរោងនឹងជួយជាថវិកាតែឥឡូវកំពុងតែសិក្សាលំអិត ។ គោលដៅធំទី ២ គឺធ្វើឱ្យយន្តការនៃការចុះឈ្មោះបោះឆ្នោតក្លាយជាយន្តការប្រចាំថ្ងៃសំរាប់ប្រជាពលរដ្ឋនៅក្នុងភូមិទាំងអស់កុំឱ្យការចុះឈ្មោះបោះឆ្នោតនៅជាបញ្ហាទៀតជាពិសេសក្នុងរយៈពេល ៩ ខែត្រៀមនិង ១ ខែការចុះឈ្មោះមែនទែន ។ គោលដៅធំទី ៣ ទាក់ទងនឹងក្រសួងមានសមត្ថកិច្ចផ្ទាល់ធ្វើឱ្យយន្តការនៃការបោះឆ្នោតបានប្រព្រឹត្តទៅគ្រប់ពេលវេលាគ្រប់យន្តការបោះឆ្នោតនៅក្នុងសភាពមិនភ័យខ្លាចហើយគណបក្សនយោបាយ ក៏អាចធ្វើសកម្មភាពទៅតាមលក្ខណៈច្បាប់ដោយគ្មានការគំរាមកំហែងដោយគ្មានការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋាន តាំងពីភូមិ ឃុំ រហូតដល់ស្រុក ខេត្ត ។ លោកក៏បានធ្វើការកត់សំគាល់ផងដែរថា ប្រទេសកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន មានការវិវឌ្ឍន៍ជឿនលឿនច្រើន ពិសេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធសូម្បីខាងផ្នែកនយោបាយក៏មានភាពចាស់ទុំច្រើនដែរ ដែលនេះមានសារៈប្រយោជន៍ជាច្រើន ក្នុងការទាក់ទាញជំនួយ និង វិនិយោគបរទេស ។

លោក **ឃឹម វុទ្ធី** ជំទប់ទី ២ ឃុំក្តាញ់ បានលើកឡើងពីការលំបាកនៅពេលដែលប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោត តែពុំមានឯកសារណាដែលពាក់ព័ន្ធ ដូចជាអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណគ្រួសារឡើយ ។ លុះនៅពេលដែលប្រាប់ឱ្យគាត់ទៅធ្វើគាត់លើកឡើងថាគ្មានលុយសំរាប់ឱ្យលោកប៉ូលីសនោះទេ ដោយសារតែគាតមានជីវភាពយ៉ាប់យឺនពេក ។ លោកបានសួរថាតើនៅថ្នាក់លើដោះស្រាយដូចម្តេចចំពោះប្រជាពលរដ្ឋដែលទីទាល់ក្រ ។ នេះជាមូលហេតុមួយដែលយើងមិនផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតគ្រប់គ្នាដោយសារគាត់គ្មានសិទ្ធិទៅធ្វើអត្តសញ្ញាណប័ណ្ណបាន ។ កាលណាគាត់អត់មានបញ្ជីគ្រួសារ អត់មានអត្តសញ្ញាណប័ណ្ណ ហាក់ដូចជាថាគ្រួសារនោះនៅក្រៅសង្គមផងដែរ ។ លោកក៏បានលើកឡើងអំពីការលំបាកមួយទៀត នៅពេលដែលប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នាត មន្ត្រីទទួលបន្ទុកចុះឈ្មោះតែងតែថាខ្វះនេះខ្វះនោះបណ្តាលឱ្យគាត់ត្រលប់ទៅផ្ទះវិញ ដែលនេះកើតឡើង ដោយសារប្រជាពលរដ្ឋទាំងនោះប្រកាន់គណបក្សនយោបាយនេះ ឬគណបក្សនយោបាយនោះ ។ លុះពេលទៅវិញ គាត់មិនត្រលប់មកធ្វើវិញ គាត់មិនមកចុះឈ្មោះដោយ គាត់ លើកឡើងថាខាតពេលវេលារកស៊ីរបស់គាត់ ។

លោក **សម សុខា** ជំទប់ទី ២ ឃុំព្រៃល្វា បានលើកបញ្ហាទាក់ទងនឹងការជ្រើសរើសមន្ត្រី **CEC** កន្លងមកដោយមិនបានសម្ភាសន៍ លោកស្នើសុំឱ្យការជ្រើសរើសលើកក្រោយគួរតែមានតម្លាភាពខ្លះដោយឱ្យមានសម្ភាសន៍ត្រឹមត្រូវ និងមានការជ្រើសរើសដោយផ្អែកលើសមត្ថភាព ។ លោកក៏បានលើកពីបញ្ហាផ្លាស់ប្តូរអ្នកបោះឆ្នោតនៅតាមការិយាល័យនីមួយៗកន្លងមក មានជួបការលំបាកដោយសារមានអ្នកមកពីចំងាយ បានរៀបអាពាហ៍ពិពាហ៍នៅថ្នាក់មូលដ្ឋាន នៅពេលគាត់ចង់ចុះបោះឆ្នោតនៅមូលដ្ឋាននេះគាត់ត្រូវមានឯកសារផ្ទេរដើម្បីបញ្ជាក់ច្បាស់លាស់ទើបអាចចុះបាន លុះនៅពេលដែលគាត់មិនមាន នាំឱ្យមានការលំបាករហូតដល់

អ្នកខ្លះមិនមានប័ណ្ណបោះឆ្នោត ដែលធ្វើឱ្យគាត់មិនអាចបោះឆ្នោតបាន ។ បញ្ហាដាក់ពាក្យបណ្តឹង ដោះស្រាយវិវាទជាមួយគណបក្សនយោបាយនៅថ្នាក់ **CEC** នៅពេលដែលវិវាទនេះហួសពីសមត្ថកិច្ចរបស់ **CEC** តែ **CEC** មិនបានបញ្ជូនមកថ្នាក់លើឡើយ គឺដោះស្រាយនៅតែត្រឹម **CEC** ដដែលធ្វើឱ្យបណ្តឹងកន្លងមកអត់មានប្រសិទ្ធិភាព ។ លោកក៏ចូលរួមលើកយកបញ្ហាអត្តសញ្ញាណប័ណ្ណដូចលោកវុទ្ធីដែលថាមានការទារលុយកាក់ពីសំណាក់មន្ត្រីប៉ូលីសដោយសំអាងថាខូះខាតនេះខូះខាតនោះ ។

លោក **ប៉ែន ឡុង** បានលើកបញ្ជាក់ពីលក្ខខ័ណ្ឌចុះឈ្មោះបោះឆ្នោតមានពីរ ទី១ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតស្រាប់ ទី២ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផ្ទាល់ខ្លួន ឬលិខិតឆ្លងដែន ឬប័ណ្ណមន្ត្រីរាជការស៊ីវិល នគរបាល ខេមរភូមិន្ទ ។ នៅពេលជិតដល់ថ្ងៃបោះឆ្នោតជនណាម្នាក់អាចរងគ្រោះដោយចោរលួចឆក់កាបូបដោយទាំងបណ្ណ័បោះឆ្នោតនោះ ឬប័ណ្ណសំគាល់ផ្សេងៗ ឬក៏អគ្គីភ័យឆាបឆេះផ្ទះអស់រលីងគ្មានសេះសល់ គ.ជ.ប មានគោលការណ៏ចេញទំរង់ ១០១៨ មួយជំនួសប័ណ្ណបោះឆ្នោត ជូនអ្នកទាំងនោះដើម្បីទៅបោះឆ្នោតបាន ប៉ុន្តែប័ណ្ណបោះឆ្នោតចាប់ពីពេលនេះទៅ គឺអស់សុពលភាពដោយឱ្យប្រើអត្តសញ្ញាណប័ណ្ណជំនួសវិញ ។ លោកបានជំរាបផងដែរថាបញ្ហាអត្តសញ្ញាណប័ណ្ណនៅស្រុកស្ទាញដោយប្រជាពលរដ្ឋភាគច្រើនអត់ទាន់មាននៅឡើយ សូម្បីតែរដ្ឋបាល ឃុំ-សង្កាត់ខ្លះក៏អត់មានអត្តសញ្ញាណប័ណ្ណនេះដែរ ពិសេសទាក់ទងនឹងការខុសឈ្មោះ អក្ខរាវិរុទ្ធ ថ្ងៃខែឆ្នាំកំណើត និងឈ្មោះស្ងួន ជាដើម ។ ដើម្បីដោះស្រាយបញ្ហាចំពោះមុខសំរាប់ការបោះឆ្នោតព្រឹទ្ធសភាខាងមុខនេះ លោកបានឱ្យក្រុមប្រឹក្សាឃុំចេញទំរង់ ១០១៨ ជូនគាត់ដោយមានបិទរូបថត ។ ទាក់ទងនឹងពាក្យបណ្តឹងមិនផ្ញើទៅថ្នាក់លើ លោកបានលើកថាមានមូលហេតុពីរ មូលហេតុទី ១ មុនតំបូងបណ្តឹងបោះឆ្នោតត្រូវដោះតាមឋានានុក្រមគឺពីថ្នាក់ **CEC** ។ បើមិនមានប្តឹងបន្តមកលើទេចាត់ទុកថាដំណោះស្រាយនៅថ្នាក់ **CEC** ភាគីបណ្តឹងបានឯកភាពតាមសេចក្តីសំរេចរបស់ **CEC** ។ មូលហេតុទី២ បើដើមបណ្តឹងមិនឯកភាពទេ តែមិនបានបំពេញទំរង់ ១២០២ ដើម្បីប្តឹងបន្តទេដូចនេះ **CEC** មិនអាចបញ្ជូនទៅ គ.ជ.ប បានឡើយ ។ លោកបានលើកឡើងថាកន្លងមក នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៣ លោកទទួលបានពាក្យបណ្តឹងតែ ៨ ទេ ហើយដោះស្រាយរួចចប់សព្វគ្រប់ទាំង ៨ បណ្តឹង ។ បណ្តឹង ៦ ពុំមានតវ៉ាទៀតទេតែមានបណ្តឹង ២ ត្រូវបានប្តឹងតវ៉ាទៅគ.ជ.ប ។ នៅពេលដល់ថ្ងៃចេញលទ្ធផលជាផ្លូវការរបស់ គ.ជ.ប ស្រាប់តែមានបណ្តឹងរហូតដល់ ២៧៨ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយក្នុងនោះខេត្តតាកែវទទួលបានលេខ ១ ខាងពាក្យបណ្តឹង ។ ទាក់ទងនឹងការជ្រើសរើសមន្ត្រីថ្នាក់ CEC ថាមានអ្នកមិនមកសម្ភាសន៏ក៏ជាប់ដែរនោះ លោកស្នើសុំឱ្យមានបង្ហាញភស្តុតាងដើម្បីថ្ងៃក្រោយលោកនឹងពិនិត្យសំរេចឡើងវិញ ។

លោកវរៈសេនីយ៏ទោ **ជិន ប៊ុក** ស្នងការរងទី១ ខេត្តតាកែវ បានបញ្ជាក់ថាការធ្វើសៀវភៅគ្រួសារ ក.៤ និងសៀវភៅស្នាក់នៅ ជាគោលការណ៏គេចាប់ដំណើរការតាំងពីឆ្នាំ ១៩៩៥ ដល់ ៩៨ ដោយមិនយកលុយទេ ហើយអាជ្ញាធរមូលដ្ឋានបានផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋឱ្យមកធ្វើសៀវភៅនេះដើម្បីទុកជាឯកសារគោល ។ រហូតដល់ឆ្នាំ ២០០៣ ប្រជាពលរដ្ឋបានមកធ្វើច្រើនដែល តាមរបាយការណ៏ទទួលបាន មាន ៨០ ទៅ ៩០ ភាគរយ ។ សំរាប់សៀវភៅស្នាក់នៅមិនមានបិទរូបថតទេ អ្នកណាក៏អាចចុះបានដែរ តែសំរាប់សៀវភៅ ក.៤ ត្រូវមានបិទរូបថតមេគ្រួសារ ។ ទាក់ទងនឹងចេញអត្តសញ្ញាណប័ណ្ណសំរាប់ប្រជាពលរដ្ឋយឺតយ៉ាវនេះ គឺដោយសារឯកឧត្តមអភិបាលខេត្តជាប់រវល់ពេក ពុំទាន់ចុះហត្ថលេខាលើប័ណ្ណនោះឱ្យបានទាន់ពេលវេលា ។ ចំពោះការទារលុយពីប្រជាពលរដ្ឋនោះគឺដោយសារបច្ចុប្បន្នពុំទាន់មានក្រុមហ៊ុនទទួលធ្វើនៅឡើយទេ ដូច្នេះហើយបានជាមានការទារលុយកាក់ខ្លះសំរាប់ការធ្វើដំណើររបស់មន្ត្រីទាំងនោះ ។

លោក **ឃុំ សារឿន** ជំទប់ទី ២ ឃុំរការក្រៅស្រុកដូនកែវ បានបញ្ជាក់ថានៅឃុំរការក្រៅកាលពីមុនចុះឆ្នោតឆ្នាំ ១៩៩៩ យុទ្ធនាការធ្វើសៀវភៅគ្រួសារនោះមានយកលុយ ២.០០០ រៀលសំរាប់មួយគ្រួសារដែលមានរូបថត បើមិនមានរូបថតតំលៃ ៨.០០០ រៀល ។ ការធ្វើអត្តសញ្ញាណប័ណ្ណក្នុងយុទ្ធនាការ គឺមានយកម្នាក់ ៥.០០០ រៀលថ្លៃសរសេរ ៥០០ ទៀតសរុប ៥.៥០០ រៀលទៅ ៦.០០០រៀល ។ ដោយឡែកនៅក្រោយយុទ្ធនាការយើងត្រូវការចំណាយលុយពិតប្រាកដមែន សូម្បីតែសាច់ឈាមបងប្អូនរបស់លោក ដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណ មកធ្វើពេលក្រោយក៏ត្រូវការឱ្យលុយគេដែរ ។ លោកក៏បានសំណូមពរផងដែរទាក់ទិននិងការបោះឆ្នោតនៅថ្ងៃមុខ ដោយសុំធ្វើយ៉ាងណាឱ្យមានការគោរពពេលវេលាទាំងអស់គ្នា ពិសេសនៅពេលឃោសនាបោះឆ្នោត បើមានកម្មវិធីរបស់គណបក្សណាទៅឃោសនានៅកន្លែងមួយ សូមគោរពគ្នាទៅវិញទៅមក ។

លោក **អ៊ុក វណ្ណារ៉ា** ជំទប់ទី២ ឃុំអង្គប្រាសាទ ស្រុកគីរីវង់បានថ្លែងអំណរគុណចំពោះ លោកស្នងការរងខេត្ត ដែលបានជួយអប់រំកែតំរូវដល់នគរបាលឈរជើងនៅតាមប៉ុស្តិ៍ដែលទារលុយយ៉ាងច្រើនពីអាជីវករ និង ប្រជាពលរដ្ឋ ហើយលោកជឿថាថ្ងៃក្រោយ និងមិនមានបញ្ហានេះទៀតទេ ។ ទាក់ទងនឹងសៀវភៅគ្រួសារ និង អត្តសញ្ញាណប័ណ្ណ លោកស្នើសុំលោកប៉ូលីសមេត្តាកុំយកលុយច្រើនពេកពីប្រជាពលរដ្ឋព្រោះប្រជាពលរដ្ឋមានជីវភាពក្រីក្រលំបាក ។ លោកបានសួរថាការបោះឆ្នោតខាងមុខនេះ តើត្រូវយកអត្តសញ្ញាណប័ណ្ណឱ្យត្រូវបញ្ជីនោះទាំងស្រុងឬមួយយ៉ាងណា? លោកបានលើកឡើងផងដែរថាលោកមេភូមិកន្លងមកបានដើរស្រង់ឈ្មោះអ្នកចុះឈ្មោះបោះឆ្នោតនៅតាមភូមិមិនបានធ្វើជាទូទៅទេ គឺមានការប្រកាន់គណបក្ស ហើយលោកសំណូមពរឱ្យខប់សែលលើកបញ្ហានេះទៅពិភាក្សាគ្នានៅថ្នាក់ជាតិ ។

លោក **សៅ មិន** ជំទប់ទី២ ឃុំត្រពាំងប្រសាទ ស្រុកបាទី បានលើកជាសំណូមពរថានៅពេលធ្វើប្រតិភូកម្មអំណាចឱ្យ ស្មៀនឃុំ ឬក្រុមប្រឹក្សាឃុំជាអ្នកចុះបញ្ជីឈ្មោះបោះឆ្នោត គួរតែគិតឱ្យបានច្បាស់លាស់ ព្រោះស្មៀនទាំងអស់នេះ នៅពេលធ្វើជំរឿន ឈ្មោះគាត់មិនបានហៅសមាជិករបស់គណបក្សផ្សេងៗទៀតមកចូលរួមទេដែលជាក់ស្តែងកើតមានច្រើននៅតំបន់របស់លោក ។ លោកក៏បានលើកសំណូមពរផងដែរ ទៅអាជ្ញាធរមូលដ្ឋានដែលត្រូវធ្វើអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ មេត្តាកុំយកលុយ ច្រើនពេកពីប្រជាពលរដ្ឋ និងជាពិសេសឯកសារទាំងនោះគួរកុំឱ្យមានលុបច្រើនពេក ។

លោក **ឱក សេរី សោភ័ក្តិ** បានលើកយកបទពិសោធន៍មួយនៅឃុំស្វាយជ្រុំ និងឃុំអន្លង់វិលខេត្តបាត់ដំបង កើតមានបញ្ហាលុបលើឯកសារទាំងនេះដែរតែពេលនោះលោកមេឃុំ និង ក្រុមប្រឹក្សាឃុំ បានធ្វើការប្រជុំភ្លាមៗជាមួយប្រជាពលរដ្ឋដើម្បីសើរើ និងធ្វើការកែតម្រូវឡើងវិញ ធ្វើឱ្យបញ្ហាបានដោះស្រាយដោយស្រួល ហើយលោកបានស្នើសុំថាបើឃុំផ្សេងៗទៀតអាចធ្វើបាននោះ ដំណោះស្រាយ នឹងកើតមាន ហើយដំណើរការនេះនឹងមានភាពល្អប្រសើរជាមិនខាន ។

ឯកឧត្តម **កង សំអឿន** បានស្នើសុំឱ្យអង្គប្រជុំលើកយកយោបល់ដែលជាដំណោះស្រាយសំរាប់បញ្ហាទាំងឡាយដែលបានលើកឡើងនេះដើម្បីយើងកែលំអរឱ្យមានតម្លាភាពទាំងអស់គ្នា ទោះជាទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតក្តី ត្រួតពិនិត្យបញ្ជីបោះឆ្នោតក្តី ការធ្វើអត្តសញ្ញាណប័ណ្ណក្តី សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅក្តី ។ ពិសេសទាក់ទងការយកលុយពេលធ្វើប័ណ្ណទាំងអស់នេះឯកឧត្តមស្នើថាសុំឱ្យលើកបង្ហាញឈ្មោះបុគ្គលដែលទារលុយនោះឱ្យចំៗ ហើយប្តឹងមកអាជ្ញាធរមានសមត្ថកិច្ចដើម្បីងាយស្រួលដោះស្រាយនិងមានវិធានការ ។ បើគាត់នៅតែអនុវត្តយ៉ាងដូច្នេះតទៀត ខេត្តនឹងមានវិធានការដោះស្រាយតាមច្បាប់រដ្ឋបាលដោយមិនទុកឱ្យបុគ្គលនោះធ្វើបែបនេះទេ នេះជាគោលការណ៍របស់ខេត្ត ហើយឯកឧត្តមនឹងចេញដោះស្រាយដោយផ្ទាល់ជាមួយប៉ូលីស ។

ទាក់ទងនឹងបញ្ហាលោកស្មៀនឃុំជាមួយនិងកុមប្រឹក្សាឃុំម្នាក់ទៀត បើតាមគោលការណ៍ណែនាំគឺមិនមាន គណបក្សនយោបាយទាំងបីនោះធ្វើទេ តែជាអ្នកសង្កេតការណ៍គឺមាន ។ បើសង្កេតការណ៍ ឃើញមិនមានភាពប្រក្រតី អាចរាយការណ៍បាន។

លោក **អឹម អូន** ក្រុមប្រឹក្សាខេត្តនៃគណបក្សសម រង្ស៊ី បានលើកបញ្ជាក់បន្ថែមអំពីបញ្ហាអត្តសញ្ញាណប័ណ្ណ ដែលនៅភូមិរបស់លោក ពីមុនពេលធ្វើមិនមានយកលុយទេប៉ុន្តែឥឡូវនេះបើចង់បានទាល់តែមានលុយទើបខាងប៉ូលីសប៉ុស្តិ៍ធ្វើឱ្យ ។ លោកស្នើសុំឱ្យមានការពិនិត្យឡើងវិញនិងបើយកប្រាក់គួរតែក្នុងកំរិតតិចតួចបំផុតព្រោះប្រជាពលរដ្ឋមានការខ្វះខាតជីវភាពច្រើន ។ លោកបានលើកឡើងពីឫសគល់នៃទំនាស់ដែលកើតមានកន្លងមកច្រើនតែដោយសារការប្រកាន់បក្សពួកគណបក្សនយោបាយ យូរៗទៅធ្វើឱ្យមានការរើសអើង និងរហូតដល់មើលមុខគ្នាមិនចំ ។ ក្នុងន័យនេះលោកស្នើសុំឱ្យមេធំៗ គួរតែបង្កលក្ខណៈងាយស្រួលធ្វើការងាររួម ដើម្បីផលប្រយោជន៍ប្រទេសជាតិ និងឱ្យប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសតំណាងរបស់ខ្លួនដោយសេរី និងសន្តិវិធី ។ លោកក៏បានសំណូមពរថាសុំគណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានសមាសភាពពហុបក្ស ព្រោះថាកន្លងមកគោលការណ៍រើសយកអ្នកអព្យាក្រឹតដើម្បីធ្វើការងារនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ឃុំ ប៉ុន្តែមិនដែលរើសបានអព្យាក្រិតទេ ភាគច្រើនមកពីគណបក្សប្រជាជនកម្ពុជា តែគណបក្សសម រង្ស៊ីមិនដែលបានចូលរួមនៅកន្លែងណាទេ បើមានទាល់តែជ្រៀតបានតិចតួចណាស់ ។ ចំពោះការដោះស្រាយពាក្យបណ្តឹងនៅពេលបោះឆ្នោត ដើម្បីឱ្យមានច្បាស់លាស់គួរបង្កើតគណកម្មការដោះស្រាយវិវាទមួយ ឯករាជ្យ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ ។ ការដែលឱ្យ គ.ជ.ប ធ្វើអាជ្ញាកណ្តាលផងអ្នកលេងផង តែងតែមានលំអៀងមិនខាន តែបើមានគណកម្មាការមួយដោយឡែកដើម្បីដោះស្រាយបញ្ហានេះ ប្រហែលជាអាចកាត់បន្ថយបញ្ហាចំរូងចំរ៉ាស់ ឬអធិករណ៍ ដែលនាំឱ្យប្រជាជនសោកសង្វៃក ។

លោកស្រី **ហាក់ សុភៈរី** ប្រធានគណៈកម្មាធិកានិកហ្វិចខេត្ត បានលើកសំណូមពរដល់រាជរដ្ឋាភិបាលអនុញ្ញាតិឱ្យមានអ្នកសង្កេតការណ៍ពេលធ្វើអត្តសញ្ញាណប័ណ្ណដើម្បីកុំឱ្យមានបញ្ហាតទៅទៀត ។ លោកស្រីបានស្នើសុំភ្នាក់ងារគណបក្សនយោបាយទាំងអស់ដែលអង្កេតការណ៍នៅការិយាល័យបោះឆ្នោត បើសិនជានៅការិយាល័យបោះឆ្នោតឃើញមានភាពមិនត្រឹមត្រូវ មិនប្រក្រតី សូមកុំចុះហត្ថលេខាលើក្រដាស់ឯកសារទទួលស្គាល់ឱ្យសោះ ដើម្បីទុកឱ្យឯកសារនោះមិនបានការ ប៉ុន្តែកាលណាចុះហត្ថលេខាគឺមានន័យថាទទួលស្គាល់សន្លឹកឆ្នោតពិតជាត្រឹមត្រូវ ។

លោក **ទាវ ចំរើន** ជំទប់ទី២ ឃុំឆ្នោត ស្រុកបាទី សុំឱ្យ គ.ជ.ប បំភ្លឺអំពីបញ្ហារូបថតពេលចុះឈ្មោះបោះឆ្នោត ហេតុអ្វីចាំបាច់មានបិទរូបថតនៅលើប័ណ្ណបោះឆ្នោតដែលធ្វើឱ្យប្រជាពលរដ្ឋជួបការលំបាកបន្ថែមទៀត ហើយការធ្វើបែបនេះអាចបងប្អូនបោះឆ្នោតអត់បានទេ ។ បញ្ហាអត្រានុកូលដ្ឋានលោកស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានជួយសម្រួលកុំឱ្យមានយកលុយច្រើនពេកដើម្បីជួយសម្រួលជូនប្រជាពលរដ្ឋ ។

លោក **ផាន សឿន** នាយកការិយាល័យប្រចាំខេត្តតាកែវ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានគាំទ្រចំពោះខប់សែលដែលបានរៀបចំជាវេទិការនេះឡើងដើម្បីជជែកពិភាក្សារកដំណោះស្រាយរួមគ្នាប្រកដោយន័យស្ថាបនា និង ឈានទៅរកការជឿទុកចិត្តគ្នាទៅវិញទៅមក និងអាចកសាងវប្បធម៌ពិភាក្សាគ្នានៅក្នុងសង្គមយើង ។ លោកបានលើកបញ្ហាមិនប្រក្រតីមួយចំនួននៅពេលចុះឈ្មោះបោះឆ្នោតមានមន្ត្រីមួយចំនួនអនុវត្តតាមនីតិវិធី តែមានមួយទៀតអនុវត្តតាមការយល់ឃើញ ឬយោគយល់ដែលធ្វើឱ្យមានបញ្ហាបាត់តុល្យភាពចំពោះប្រជាពលរដ្ឋដោយមួយចំនួនបានចុះឈ្មោះ និងមួយចំនួនទៀតអត់បានចុះឈ្មោះ ។ លោកស្នើសុំឱ្យ PEC មេត្តាជួយអប់រំដល់មន្ត្រីទាំងនោះបន្ថែមទៀតដើម្បីឱ្យគាត់ទទួលខុសត្រូវឱ្យបានល្អស្របតាមនីតិវិធី ។ ទាក់ទងនឹងការចុះឈ្មោះ បោះឆ្នោតដែល

ថាមានអាណិកជនចុះឈ្មោះផងដែរលោកស្នើសុំឱ្យគណបក្សនយោបាយទាំងអស់គួរទទួលស្គាល់ថាNEC មានភារកិច្ចត្រឹមតែចុះឈ្មោះឱ្យត្រូវតាមគោលការណ៍នីតិវិធីចុះឈ្មោះតែប៉ុណ្ណោះ ប៉ុន្តែទាក់ទងនឹងសិទ្ធិចុះឈ្មោះបានឬមិនបាន នោះស្ថិតនៅលើលក្ខខ័ណ្ឌមួយផ្សេងទៀត ។ លោកបានស្នើសុំកុំឱ្យមានការចែកអំណោយនៅពេលយុទ្ធនាការឃោសនាបោះឆ្នោតឱ្យសោះ ព្រោះនាំឱ្យមានការខ្វែងគំនិតគ្នា និង នាំឱ្យមានការចោទប្រកាន់គ្នាទៅវិញទៅមក ។

លោក **ហ៊ឹម វុឌ្ឍី** ជំទប់ទី ២ ឃុំបាស្រែ បានលើកចំនុចទាក់ទងការចុះឈ្មោះបោះឆ្នោតសំរាប់អ្នកថ្មី ដែលមិនមានប្រើទំរង់ ១០២០ សំរាប់ឱ្យអ្នកសង្កេតការណ៍ជជែកវែកញែកគ្នាឡើយ ។ ជាក់ស្តែងនៅឃុំបាស្រែលោកស្មៀនឃុំចុះឈ្មោះបោះឆ្នោត ដោយចេញតែចុងសន្លឹកឱ្យមួយគេហៅថា ១០២០ តែពុំមានទំរង់ ១០១៨ ឡើយ ។ លោកបានសួរទៅ PEC ថាតើអាចសម្រួលបានទេប្រសិនជាអត្តសញ្ញាណប័ណ្ណថ្ងៃខែឆ្នាំកំណើតគាត់ផ្សេងពីប័ណ្ណចុះឈ្មោះបោះឆ្នោតលើកមុន ហើយនៅពេលបោះឆ្នោតគាត់អាចកាន់អត្តសញ្ញាណប័ណ្ណនោះទៅបោះឆ្នោត ? ទាក់ទងនឹងទំរង់ ១០១៨ កន្លងមកមានចេញទំរង់ ១០១៨ ជូនគាត់កាន់ដើម្បីចូលរួមបោះឆ្នោត ឥឡូវនេះមានអ្នកខ្លះបាត់ទំរង់នោះ តើអាចចេញទំរង់ ១០១៨ ជូនគាត់ម្តងទៀតបានទេ ? បញ្ហាអត្តសញ្ញាណប័ណ្ណ មានអ្នកអត់ទាន់មានច្រើន សូម្បីតែក្រុមប្រឹក្សាឃុំសុទ្ធតែជាអ្នកមានចំណេះដឹងខ្ពស់ៗនៅមានអត់អត្តសញ្ញាណប័ណ្ណ ។

លោក **ឃន សុខេង** ប្រធានក្រុមប្រឹក្សាឃុំបាកាបស្រុកព្រៃកប្បាស បានលើកឡើងបញ្ហាបាត់ឈ្មោះអ្នកបោះឆ្នោតពីបញ្ជីឈ្មោះបោះឆ្នោតដោយសារចំណុចពីរ ទី១ គឺដោយសារក្រុមប្រឹក្សាឃុំដែលធ្វើការចុះឈ្មោះលោកប្រកាន់គណបក្សនយោបាយ ហើយគាត់មិនពេញចិត្តបុគ្គលណាដែលប្រកាន់គណបក្សនយោបាយផ្សេង នៅពេលបុគ្គលនោះមកចុះឈ្មោះបោះឆ្នោតធ្វើឱ្យឈ្មោះរបស់គាត់អត់មាននៅក្នុងបញ្ជីបោះឆ្នោតដែលធ្វើឱ្យគាត់មិនអាចបោះឆ្នោតបានឡើយ ។ ទី២ មានគណបក្សខ្លះទៅហៅប្រជាជនឱ្យចុះឈ្មោះធ្វើប័ណ្ណបោះឆ្នោត តែជាក់ស្តែងរើសធ្វើជាសមាជិកគណបក្សទៅវិញ ដែលធ្វើឱ្យប្រជាពលរដ្ឋច្រឡំ ។

លោក **អ៊ុន វណ្ណា** ប្រធានរដ្ឋបាលមូលដ្ឋានខេត្តតាកែវ បានបញ្ជាក់ថានៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ និង អនុក្រឹត្យអំពីការធ្វើប្រតិភូកម្មអំណាចបានកំណត់ច្បាស់ហើយថា ក្រុមប្រឹក្សាឃុំមុនពេលចូលកាន់តំណែងរយះពេលមួយខែត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ដូច្នេះបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំសង្កាត់បានកំណត់ពីរបៀបធ្វើការងារ របៀបប្រជុំក្នុងក្រុមប្រឹក្សាថ្មី ។ បញ្ហាទំនាស់អស់ទាំងនេះអាចលើកបាននៅក្នុងការប្រជុំក្រុមប្រឹក្សាឃុំដើម្បីសំរេចអនុម័ត និងត្រូវដោះស្រាយ ។ ឧទាហរណ៍ ការធ្វើបណ្ណ័គ្រួសារ មានយកលុយប្រជាពលរដ្ឋពីរម៉ឺន យកពីឈ្មោះណា អាចលើកឡើងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំបាន ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំអាចប្រជុំជាសាធារណៈមិនមែនប្រជុំជាសម្ងាត់ទេ ប្រជាពលរដ្ឋនៅក្នុងឃុំ តំណាងអង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើសកម្មភាព គណបក្សនយោបាយអាចចូលរួមបាន ដើម្បីលើកឡើងបញ្ហាដោះស្រាយ នៅក្នុងក្រុមប្រឹក្សាឃុំ ចំណុចដែលមិនត្រូវដោះស្រាយ បើសំរេចជាចំហរមិនបានគឺបោះឆ្នោតជាសំងាត់ ។ កិច្ចការងារនេះគួរតែប្រើប្រាស់នីតិវិធី ដើម្បីដោះស្រាយទំនាស់ក្នុងក្របខណ្ឌ័ក្រុមប្រឹក្សាឃុំឱ្យបានច្រើន ព្រោះដើម្បីពង្រឹងអំណាចប្រជាធិបតេយ្យដែលរដ្ឋាភិបាលបានផ្ទេរទៅឱ្យឃុំ ។ ព្រោះកន្លងមកគឺមានឃុំខ្លះ ៥-៦ ខែមិនទាន់ប្រជុំម្តងផង ដូចនេះអ្នកនៅក្នុងក្រុមប្រឹក្សាឃុំជំទប់ទី១ ទី២ ត្រូវតែរួមចំណែកខុស ក្នុងការមិនបានប្រជុំនេះ ព្រោះច្បាប់កំណត់ឱ្យមួយខែប្រជុំមួយដង ។ លោកមេឃុំមិនបានកោះអញ្ជើញប្រជុំ ជំទប់ទី១ ទី២ អាចធ្វើសេចក្តីស្នើប្រជុំ ហើយយន្តការខប់សែលនេះមានសារៈសំខាន់ណាស់ ដែលក្រុមប្រឹក្សាឃុំគួរយកជាគំរូសំរាប់កិច្ចប្រជុំរបស់ខ្លួនប្រចាំខែ ។ ដើម្បីចូលរួមចំណែកឱ្យកាន់តែមានតម្លាភាពនៅមូលដ្ឋាន គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ ត្រូវបានបង្កើត និងបានរៀបចំ ។ ការងារគណនេយ្យភាព មូលនិធិឃុំសង្កាត់ បានដាក់ប្រអប់សំបុត្រ ហើយដាក់ទាំងសំបុត្រទៅគ្រប់ឃុំប៉ុន្តែទៅមិនទាន់ដល់ទេ ។

នៅទូទាំងខេត្តមាន ១៣០ ប្រអប់ មន្ទីរជុំវិញខេត្តអង្គការក្រៅរដ្ឋាភិបាល និងសាលាស្រុក បញ្ហាដែលមានលើកឡើងអាចសរសេរលើក្រដាសក្នុងស្រោមសំបុត្រ រួចដាក់ចូលប្រអប់សំបុត្រនេះ ។ ប្រអប់នេះតាមនីតិវិធីយកពីឃុំណាត្រូវសរសេរនៅឃុំនោះ តែមិនអាចដាក់នៅឃុំដូចគ្នាបានទេ គឺអាចដាក់នៅឃុំណាក៏បានដែរ ហើយសំបុត្រនេះនឹងដល់កន្លែងលោកអភិបាលខេត្តដែលជា ប្រធានក្រុមការងារគណនេយ្យភាព ។ ព័ត៌មាននឹងទទួលបាននៅទីនេះទាក់ទងនឹងមូលនិធិឃុំ បើពាក់ព័ន្ធនិងសមត្ថកិច្ច លោកអភិបាល នឹងបញ្ជូនទៅសមត្ថកិច្ចពាក់ពន្ធ័ដើម្បីធ្វើការដោះស្រាយ ។ ពាក់ព័ន្ធនិងការចុះឈ្មោះបោះឆ្នោតតាមខ្លឹមសារស្មារតីអនុក្រឹត្យលេខ ១០៣ ក៏ដូចជា ៦១-៦២ របស់រដ្ឋាភិបាលស្តីពីអត្រានុកូលដ្ឋានបានកំណត់ថា រដ្ឋាភិបាលនឹងប្រើប្រាស់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតជាអត្តសញ្ញាណប័ណ្ណពិតប្រាកដរបស់ប្រជាពលរដ្ឋ ។ ក្នុងពេលកំពុងយុទ្ធនាការនេះ មិនអនុញ្ញាតិឱ្យមានយកលុយពីប្រជាពលរដ្ឋដែលចុះសំបុត្រកំណើតច្បាប់ដើម បញ្ជាក់កំណើតច្បាប់ដើម ។ ជាការល្អដែលរដ្ឋាភិបាលបានពន្យាពេលមួយឆ្នាំទៀត រហូតដល់ថ្ងៃ៣០សីហា ២០០៦ ទើបចប់ ។ ក្នុងនេះដែរមានក្រុមចល័តនៃការចុះអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋតាមឃុំនេះភាគច្រើន ជាមេឃុំ ជំទប់ទី១ ជំទប់ទី២ ស្មៀន និងសមាជិកក្រុមប្រឹក្សាឃុំស្ទើរតែ ៩៩ ភាគរយជាសមាជិកក្រុមចល័តចុះអត្រានុកូលដ្ឋាននេះ។ ចំនុចដែលទាមទារឱ្យមានចំរុះបក្សនយោបាយ គឺមានគ្រប់សង្កេតការណ៏ខ្លួនឯងធ្វើការខ្លួនឯង ។ បើតាមលោកទទួលពាក្យបណ្តឹង នៅមានអ្នកឆ្បៀតយកបីបួនពាន់សំរាប់អត្រានុកូលដ្ឋានមួយសន្លឹក ។

ទាក់ទងនឹងការបោះឆ្នោតអ្នកអង្កេតការណ៏របស់គណបក្សនយោបាយនីមួយៗ នៅតាមការិយាល័យបោះឆ្នោត ពេលបោះឆ្នោត គាត់ចុះហត្ថលេខាលើកំណត់ហេតុបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត អ្នកអង្កេតការណ៏ចុះហត្ថលេខាលើកំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោត និងលទ្ធផលរបស់សន្លឹកឆ្នោតមួយៗ ប៉ុន្តែទៅដល់ទីស្នាក់ការគណបក្សនយោបាយ គាត់រាយការណ៏ថាបានចេញពាក្យបណ្តឹងមិនទទួលស្គាល់លទ្ធផលការបោះឆ្នោត ។ លោកសូមស្នើទៅគណបក្សនយោបាយទាំងអស់ថា មុននឹងបញ្ជូនភ្នាក់ងាររបស់ខ្លួនទៅសង្កេតការណ៏នៅកន្លែងបោះឆ្នោតនីមួយៗនិងរាប់សន្លឹកឆ្នោត សូមឱ្យបណ្តុះបណ្តាលអំពីនីតិវិធីសង្កេតការណ៏ និងការចុះហត្ថលេខាឱ្យច្បាស់លាស់ដើម្បីជៀសវាងបញ្ហា ។

លោក **ប៉ែន ឡុង** បានជំរាបជូនថា បណ្ណ័បោះឆ្នោតប្រហែល នឹងឈប់ប្រើប្រាស់បន្ទាប់ពីការធ្វើបច្ចុប្បន្នភាព ឆ្នាំ២០០៥ នេះចប់ ដោយយកអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ទំរង់ ១០១៨ មានរូបថតជំនួសវិញ ពិសេសប្រហែលជាចាប់អនុវត្តនៅឆ្នាំ ២០០៧ ។ លក្ខខ័ណ្ឌអាចបោះឆ្នោតបាន មានតែពីរទេមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬមានលិខិតអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ប័ណ្ណសំគាល់ខ្លួន មន្ត្រីរាជការស៊ីវិលដែលចេញដោយក្រសួង ប័ណ្ណសំគាល់ខ្លួនរបស់កងនគរបាលជាតិ ប័ណ្ណសំគាល់ខ្លួនកងរាជអាវុធហត្ថ និងយោធា សង្ឃដីការបស់គណៈមហានិកាយ សុទ្ធិប័ត្ររបស់គណៈធម្មយុតិកនិកាយ ។ លោកបានសង្កេតឃើញថា កន្លងមក មិនដែលមានពាក្យបណ្តឹងណាមួយចេញពីមូលដ្ឋានទេ ទើបតែចូលរួមកិច្ចប្រជុំនេះបានដឹងថាមានលើកពាក្យបណ្តឹងច្រើន ។ លោកបានជំរាបថា បើឃើញភាព មិនប្រក្រតីសូមប្រញាប់ធ្វើពាក្យទំរង់ ១២០២ ដោយមានសរសេរឱ្យច្បាស់ណាស់ថា ខុសអ្វីអ្នកណាធ្វើខុស ។ លោកស្នើសុំគ្រប់គណបក្សនយោបាយមេត្តាស្គាល់សមាជិករបស់ខ្លួនឱ្យបានច្បាស់មុននឹងចាត់ចែងឱ្យធ្វើអ្នកសង្កេតការណ៏ ។

លោក **ឱក សេរី សោភក្តិ** បានសរុបខ្លឹមសារចំនួន ១៤ ចំនុចដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំព្រឹកនេះរួមមាន :

- ទី១. ឧប់សែលប្រ៉មទីមួយ មានកិត្តិយស់ណាស់ដោយមានវត្តមាន និង ប្រសាសន៍បើកជាផ្លូវនៃយន្តការឧប់សែលប្រ៉មរបស់ឯកឧត្តមអភិបាលខេត្តរង ។

- ទី២ លោក ប៉ែន ឡុងប្រធាន PEC ខេត្តតាកែវបានរាយការណ៍អំពីការរៀបចំការបោះឆ្នោតនៅខេត្តតាកែវ ក្នុងពេលបីឆ្នាំខាងមុខនេះ ។
- ទី៣ បញ្ហាចុះឈ្មោះបោះឆ្នោត ដែលមានទាក់ទងនឹងសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ការយកលុយ នៅតែកើតមានបញ្ហាច្រើនដែលយើងនឹងបន្តតាមដាន មើលបញ្ហាតទៅទៀត ។
- ទី៤ អត្តសញ្ញាណប័ណ្ណនឹងក្លាយជាឯកសារគោលសំរាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ចាប់ពី ២០០៥ នេះទៅ ។ បញ្ហាយកលុយពេលធ្វើអត្តសញ្ញាណប័ណ្ណនេះក៏បានស្តាប់ការបកស្រាយអំពីក្រសួងមានសមត្ថកិច្ច ពិសេសឯកឧត្តមអភិបាលរង បានធ្វើការធានាជាផ្លូវការដើម្បីរកដំណោះស្រាយមួយដែលនឹងបញ្ចប់ការយកលុយក្រៅផ្លូវការដោយស្នើសុំឱ្យមានការដាក់ពាក្យបណ្តឹងមកខាងអាជ្ញាធរខេត្តផ្ទាល់តែម្តងដើម្បីដោះស្រាយ ។
- ទី៥ ការជ្រើសរើសមន្ត្រីនៅថ្នាក់ CEC មានការតវ៉ាថាមិនមានលក្ខណៈតម្លាភាព
- ទី៦ ពេលដោះស្រាយពាក្យបណ្តឹងសូមឱ្យគណបក្សនយោបាយ ជាពិសេសភ្នាក់ងារ គណបក្សនយោបាយ បើសិនជាមិនគាំទ្រសូមកុំចុះហត្ថលេខា ។
- ទី៧ តួនាទីមេឃុំដែលនៅជិតជាមួយប្រជាជនក្នុងការធ្វើអត្តសញ្ញាណប័ណ្ណក្តី ក្នុងការចុះឈ្មោះបោះឆ្នោតក្តី ជាមួយនិងស្មៀនឃុំមានសារៈសំខាន់ណាស់ ដូច្នេះត្រូវតែមានសហប្រតិបត្តិការណ៍ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ។
- ទី៨ នៅពេលធ្វើយុទ្ធនាកាឃោសនាបោះឆ្នោត ស្នើសុំភាគីពាក់ព័ន្ធទាំងអស់បង្កលក្ខណៈឱ្យមានភាពរលូនដើម្បីជៀសវាងការបង្កើតបរិយាកាសរំខាន ឬបរិយាកាសមិនធានានូវសុវត្ថិភាព ។
- ទី៩ ស្នើសុំកុំឱ្យមានការចែកអំណោយនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត និងសុំឱ្យធ្វើតាមនីតិវិធី ។
- ទី១០ អង្គប្រជុំបានលើកឡើងពីអំណាចរបស់ គ.ជ.ប ក្នុងការផាកពិន័យនៅមានកំរិត នៅពេលដែលមានអ្នកធ្វើខុស ព្រោះមកដល់ពេលនេះ គ.ជ.ប ច្រើនតែប្រើយុទ្ធវិធីសម្របសម្រួលដែលជួនកាលមានប្រសិទ្ធិភាពជួនកាលគ្មានប្រសិទ្ធិភាព ។
- ទី១១ មានគណបក្សនយោបាយមួយចំនួនធ្វើការបោកប្រាស់ប្រជាពលរដ្ឋដោយទៅណែនាំឱ្យថតរូបចុះឈ្មោះបញ្ជាក់ថាធ្វើអត្តសញ្ញាណប័ណ្ណចុះឈ្មោះបោះឆ្នោត ប៉ុន្តែតាមពិតធ្វើបញ្ជីសមាជិកគណបក្សនយោបាយទៅវិញ បញ្ហានេះគួរតែបញ្ឈប់ ។
- ទី១២ មានស្នើសុំដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យយកយន្តការខប់សែលនេះ ទៅធ្វើការអនុវត្តន៏នៅក្នុងការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំសង្កាត់ផ្ទាល់ដើម្បីបង្ការ និងដោះស្រាយទំនាស់ ។

ឯកឧត្តម **កង សំអឿន** បានគូសបញ្ជាក់ថា ការលើកឡើងពីបទពិសោធន៏កន្លងមកនេះជាចំណុចល្អ និងជាមេរៀនសំរាប់ទប់ស្កាត់បញ្ហាដែលអាចកើតមាននៅពេលខាងមុខ និងជៀសវាងការប្រើប្រាស់អំពើហិង្សាដោយផ្អែកលើការដោះស្រាយតាមនីតិវិធីនៃច្បាប់ ។ មុននិងបញ្ចប់ឯកឧត្តមបានផ្តាំផ្ញើថា សូមឱ្យមន្ត្រីមូលដ្ឋាន ពិសេសក្រុមប្រឹក្សាឃុំ មេត្តាយកចិត្តទុកដាក់អនុវត្តតាមក្រឹត្យក្រមច្បាប់ដែលមានចែងឱ្យបានត្រឹមត្រូវ ក្នុងការដោះស្រាយបញ្ហានៅមូលដ្ឋានដោយសន្តិវិធី និងសុំឱ្យលើកឡើងនូវមូលហេតុឱ្យ បានច្បាស់បើមានបញ្ហាអ្វីមួយដើម្បីងាយស្រួលដោះស្រាយ ។ នៅក្នុងសន្ទរកថាបិទអង្គប្រជុំខប់សែលប្រ៉ម ឯកឧត្តមបានថ្លែងអំណរគុណដល់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា ដែលបានបង្កើតកម្មវិធីនេះដើម្បីធ្វើការស្វែងយល់ទាំងអស់គ្នារួមចំណែកទាំងអស់គ្នា ក្នុងការធ្វើឱ្យមាតុភូមិកម្ពុជាទទួលនូវសន្តិភាព ស្ថេរភាព និង គ្មានអំពើហិង្សា ។